**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា**

# សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា

កាលពីថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង៩ព្រឹក នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានបើកកិច្ចប្រជុំបន្តរបស់ខ្លួនតាមកម្មវិធីដែលបានព្រមព្រៀងគ្នានាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ ដើម្បីពិនិត្យសម្រេចចុងក្រោយលើតួលេខប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០។ គិតចាប់ពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានសម្របសម្រួលឱ្យមានកិច្ចប្រជុំផ្ទៃក្នុងបន្ថែមចំនួន ៨លើក កិច្ចប្រជុំទ្វេភាគីចំនួន ៦លើក និងកិច្ចប្រជុំត្រីភាគីចំនួន ៦លើក។

ទោះបីជាមានកិច្ចប្រជុំជាច្រើនលើក ភាគីពាក់ព័ន្ធមិនបានឯកភាពគ្នាជាឯកច្ឆន្ទលើតួលេខណាមួយឡើយ ដោយភាគីតំណាងកម្មករនិយោជិតរក្សាតួលេខចុងក្រោយរបស់ខ្លួន ១៩៥ដុល្លារអាមេរិក ភាគីតំណាងនិយោជករក្សាតួលេខ ១៨៦ដុល្លារអាមេរិក និងភាគីរាជរដ្ឋាភិបាលដោយឈរលើលក្ខណៈបច្ចេកទេស និងវិទ្យាសាស្ត្រកំណត់យកតួលេខ ១៨៧ដុល្លារអាមេរិក។

យោងតាមមាត្រា១២ នៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានអនុវត្តនូវនីតិវិធីបោះឆ្នោតជាសម្ងាត់ ដើម្បីគាំទ្រតួលេខនីមួយៗ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តួលេខចំនួន ១៩៥ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ៨សំឡេង លើ ៥១សំឡេង
- តួលេខចំនួន ១៨៧ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ៤៣សំឡេង លើ ៥១សំឡេង
- តួលេខចំនួន ១៨៦ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ០សំឡេង លើ ៥១សំឡេង

ឈរលើលទ្ធផលនៃការបោះឆ្នោតនេះ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាសូមស្នើតួលេខចំនួន ១៨៧ (មួយរយប៉ែតសិបប្រាំពីរ) ដុល្លារអាមេរិក ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការពិនិត្យសម្រេចលើប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២០ ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ តទៅ ស្របទៅតាមបទប្បញ្ញត្តិជាធរមាននៃច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។ ភាគីរាជរដ្ឋាភិបាល នឹងបន្តសម្របសម្រួលពិនិត្យលើសំណើបន្ថែមរបស់ភាគីនីមួយៗ។

*ថ្ងៃសុក្រ ៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩*

| | | |
|---|---|---|
| **ប្រធានក្រុមប្រឹក្សាជាតិ ប្រាក់ឈ្នួលអប្បបរមា** | **អនុប្រធានតំណាងអង្គការវិជ្ជាជីវៈ របស់និយោជក** | **អនុប្រធានតំណាងអង្គការវិជ្ជាជីវៈ របស់កម្មករនិយោជិត** |
| បណ្ឌិត **អ៊ិត សំហេង** | ឧកញ៉ាបណ្ឌិត **ណាង សុធី** | **សោម អូន** |